៧



# សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

## និយមន័យ

សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់តម្រូវថាជនជាប់ចោទ និងមេធាវីរបស់ពួកគេទទួលបានការជូនដំណឹងភ្លាមៗ និងព័ត៌មានលម្អិតដូចជា៖

ប្រភេទនៃការចោទប្រកាន់៖ ច្បាប់ដែលប្រើសម្រាប់ចោទប្រកាន់ទៅលើជនជាប់ចោទ។

មូលហេតុនៃការចោទប្រកាន់៖ អង្គហេតុនៃបទចោទប្រកាន់ដែលជាមូលដ្ឋានសម្រាប់ចោទប្រកាន់ទៅលើជនជាប់ចោទ។

ជនជាប់ចោទត្រូវតែទទួលបានការជូនដំណឹងឱ្យបានភ្លាមៗនៅពេលដែលពួកគេត្រូវបានចោទប្រកាន់ជាផ្លូវការស្របតាមច្បាប់ជាតិ ឬភ្លាមៗនៅពេលដែលជននោះត្រូវបានចោទប្រកាន់ជាសាធារណៈ។ ព័ត៌មានគ្រប់គ្រាន់អាចផ្តល់ជូនជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ បើទោះបីការជូនដំណឹងដំបូងដោយផ្ទាល់មាត់ក៏ដោយ ក៏ត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរតាមក្រោយផងដែរ។ ជនជាប់ចោទក៏ត្រូវ ទទួលបានព័ត៌មាននេះជាភាសាដែលពួកគេចេះ និងភាសាសាមញ្ញ និងមិនមែនក្នុងទម្រង់បច្ចេកទេស ដើម្បីធានាថាជនជាប់ ចោទអាចយល់ពីការចោទប្រកាន់នោះបាន។

## ក្របខ័ណ្ឌច្បាប់

### ច្បាប់អន្តរជាតិ



សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មានចែងការពារយ៉ាងច្បាស់ដោយ មាត្រា ១៤(៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "ក្នុងការសម្រេចសេចក្តីចោទប្រកាន់បទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមាដោយស្មើភាពគ្នាយ៉ាងពេញលេញត្រូវបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន។"

### ច្បាប់ជាតិ

សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ គឺត្រូវបានការពារដោយមាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា "ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទឱ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់លើខ្លួន" រួមទាំងមានចែងក្នុងមាត្រា ៣៣០, ៣៣១ និង៣៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ហើយក៏មានចែងនៅក្នុងមាត្រា ៦ និងមាត្រា ៥១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ។



# សារសំខាន់

សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ទាំងនៅដំណាក់កាលមុនពេលជំនុំជម្រះ និងក្នុងដំណាក់កាលនៃការជំនុំជម្រះគឺមានសារសំខាន់ណាស់ដើម្បីៈ



ធានាថាជនជាប់ចោទដឹងអំពីមូលហេតុ ដែលខ្លួនត្រូវបានចោទប្រកាន់។



ធានាថាជនជាប់ចោទអាចជំទាស់នឹងការឃុំឃាំងណាមួយដែលខ្លួនត្រូវទទួលរងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។



ត្រូវធានាថាជនជាប់ចោទមានឱកាសការពារក្តីបានល្អបំផុតតាមដែលអាចធ្វើបាន និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី។



ដើម្បីការពារជនជាប់ចោទពីបទចោទប្រកាន់ព្រហ្មទណ្ឌដែលគ្មានមូលដ្ឋាន។

អាស្រ័យហេតុនេះ ប្រការដែលអាជ្ញាធរមិនគោរពសិទ្ធិនេះអាចធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ជនជាប់ចោទនៅក្នុងការការពារក្តីរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ពីការចោទប្រកាន់មកលើខ្លួន និងដែលនាំឱ្យមានការផ្តន្ទាទោសខុស។

# ដែនកំណត់




មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលចែងអំពីសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ គឺមិនបានដាក់បញ្ចូលក្នុងបញ្ជីនៃសិទ្ធិដែលមិនអាចធ្វើបដិប្បញ្ញត្តិបាន ក្នុងករណីប្រទេសជាតិស្ថិតនៅស្ថានភាពអាសន្ននោះទេ។ ទោះយ៉ាងណាក៏ដោយលក្ខខណ្ឌរក្សាសិទ្ធិទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលចែងក្នុងមាត្រា ១៤ នេះ នឹងមានវិសមិតភាពជាមួយនឹងកម្មវត្ថុ និងគោលបំណងនៃនៃកតិកាសញ្ញាអន្តរជាតិនេះ។ ដូច្នេះការអនុវត្តទាំងឡាយណាដែលងាកចេញពីគោលការណ៍មូលដ្ឋាននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌គឺត្រូវបានហាមឃាត់គ្រប់ពេលទាំងអស់។

សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ អាចអនុវត្តបានតែពេលមានការសម្រេចចោទប្រកាន់ជនជាប់ចោទប៉ុណ្ណោះ ពោលគឺមិនមែននៅក្នុងដំណើរការនីតិវិធីស៊ើបអង្កេតព្រហ្មទណ្ឌដែលធ្វើការចោទប្រកាន់នោះទេ។ សិទ្ធិទទួលបានការជូនដំណឹងអំពីមូលហេតុនៃការចាប់ខ្លួននៅក្នុងដំណាក់កាលស៊ើបអង្កេតរឿងព្រហ្មទណ្ឌ និងនៅមុនពេលការចោទប្រកាន់ជាផ្លូវការ គឺត្រូវបានធានានៅក្នុងមាត្រាមួយផ្សេងទៀតនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មាត្រា ៩ (២))។



*សិទ្ធិមិនអាចធ្វើបដិប្បញ្ញត្តិ ជាសិទ្ធិដែលការអនុវត្តនូវសិទ្ធិនេះមិនអាចព្យួរដោយរដ្ឋាភិបាលទេនៅក្នុងស្ថានភាពនៃ "រដ្ឋស្ថិតនៅក្នុងគ្រាអាសន្ន" នៅក្នុងមាត្រា ៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ដូច្នេះការអនុវត្តទាំងឡាយណាដែលងាកចេញពីគោលការណ៍មូលដ្ឋាននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺត្រូវបានហាមឃាត់គ្រប់ពេលទាំងអស់។

ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

Sweden Sverige

People Change the World Diakonia

CC BY NC SA